## [បញ្ចូលឈ្មោះក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋានដែលបានធានា]

## ផែនការផ្លាស់ប្ដូរទីកន្លែងសង្គ្រោះបន្ទាន់ដែលជាគំរូសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការលួចតាមចាប់

**ការផ្លាស់ប្ដូរទីកន្លែងសង្គ្រោះបន្ទាន់**

**[បញ្ចូលឈ្មោះក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋានដែលបានធានា (អក្សរកាត់ HP សម្រាប់គោលបំណងនៃផែនការជាគំរូនេះ)]**

មានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់អ្នកជួលលំនៅដ្ឋានរបស់ខ្លួន ហើយក៏ធ្វើឲ្យមានការព្រួយបារម្ភ ពន្យាពេលបន្តចំពោះអ្នកជួលលំនៅដ្ឋាននានាដែលជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការលួចតាមចាប់។ ដោយអនុលោមតាមច្បាប់ស្តីពីអំពើហិង្សាប្រឆាំងស្ត្រី (VAWA),[1] ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP អនុញ្ញាតឱ្យអ្នកជួលលំនៅដ្ឋាន ដែលជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការលួចតាមចាប់ ដើម្បីស្នើសុំ ការផ្លាស់ប្ដូរទីកន្លែងសង្គ្រោះបន្ទាន់ពីលំនៅដ្ឋានអ្នកជួលនាពេលបច្ចុប្បន្ន ទៅកាន់លំនៅដ្ឋានមួយផ្សេងទៀត។ សមត្ថភាពក្នុងការស្នើសុំផ្លាស់ប្ដូរទីកន្លែង ដែលអាចប្រព្រឹត្តទៅបាន ដោយមិនគិតពីភេទ អត្តសញ្ញាណយេនឌ័រ ឬទំនោរផ្លូវភេទឡើយ។[2] ទោះជាយ៉ាងណាក៏ដោយ ក៏សមត្ថភាពក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ដើម្បីទទួលយកសំណើសុំបែបនេះសម្រាប់អ្នកជួលលំនៅដ្ឋាននានាដែល ទទួលបានជំនួយនាពេលបច្ចុប្បន្ន អាចអាស្រ័យលើសេចក្តីសម្រេចបឋម ដែលអ្នកជួលលំនៅដ្ឋានជាជនរងគ្រោះ ឬជាជនរងគ្រោះនៃ អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការលួចតាមចាប់ ហើយថាតើក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មានលំនៅដ្ឋានស្នាក់នៅផ្សេងទៀត ដែលអាចមាន និងមានសុវត្ថិភាព ដើម្បីផ្តល់ជូនអ្នកជួលលំនៅដ្ឋានសម្រាប់ ការកាន់កាប់បណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ច្រើនថែមទៀតផងដែរ។

ផែនការនេះ បញ្ជាក់ឈ្មោះអ្នកជួលលំនៅដ្ឋាននានាដែលមានសិទ្ធិស្របច្បាប់ចំពោះការផ្លាស់ប្ដូរទីកន្លែងសង្គ្រោះបន្ទាន់, ឯកសារដែលត្រូវការដើម្បីស្នើសុំការផ្លាស់ប្ដូរទីកន្លែងសង្គ្រោះបន្ទាន់, ការការពារ ព័ត៌មានសម្ងាត់, របៀបនៃការផ្លាស់ប្ដូរទីកន្លែងសង្គ្រោះបន្ទាន់អាចកើតឡើង, និងណែនាំដល់អ្នកជួលលំនៅដ្ឋាននានាអំពីសុវត្ថិភាព និងសន្តិសុខ។ ផែនការនេះ រៀបចំឡើងយោងទៅតាមផែនការផ្លាស់ប្ដូរទីកន្លែងសង្គ្រោះបន្ទាន់ដែលជាគំរូ ដែលបានចុះផ្សាយដោយក្រសួងអភិវឌ្ឍន៍លំនៅដ្ឋាន និងទីក្រុងសហរដ្ឋអាមេរិក (HUD), ទីភ្នាក់ងារសហព័ន្ធដែលត្រួតពិនិត្យថា **[បញ្ចូលឈ្មោះកម្មវិធី ឬជំនួយជួលលំនៅដ្ឋាននៅទីនេះ]** ដោយអនុលោមតាមច្បាប់ VAWA។

---

[1] បើទោះជាឈ្មោះនៃច្បាប់នេះ គឺជាការការពារច្បាប់ VAWA ដែលអាចប្រើចំពោះជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការលួចតាមចាប់ក៏ដោយ ក៏មិនគិតពីភេទ អត្តសញ្ញាណយេនឌ័រ ឬទំនោរផ្លូវភេទ។

[2] អ្នកផ្តល់សេវាកម្មលំនៅដ្ឋាន មិនអាចរើសអើងដោយផ្អែកលើមូលដ្ឋាននៃបុគ្គលិកលក្ខណៈការពារណាមួយ ដែលរួមមានជាតិសាសន៍ សម្បុរ, ដើមកំណើតជាតិសាសន៍ សាសនា ភេទ ស្ថានភាពគ្រួសារ ពិការភាព ឬអាយុ។ លំនៅដ្ឋាន HUD-ជំនួយ និង HUD-ធានា ត្រូវរៀបចំឡើងដែល អាចរកបានសម្រាប់បុគ្គលមានសិទ្ធិស្របច្បាប់តាមបែបផ្សេងទាំងអស់ ដោយមិនគិតពីទំនោរផ្លូវភេទដែលឃ្លាំមើល ឬជាក់ស្តែង អត្តសញ្ញាណ
យេនឌ័រ ឬមានគ្រួសារឬអត់។

### ភាពមានសិទ្ធិស្របច្បាប់ចំពោះការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់

អ្នកជួលលំនៅដ្ឋានម្នាក់ដែលជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ មួយដូចមានចែងក្នុងបទប្បញ្ញត្តិ HUD នៅត្រង់ចំណុច 24 CFR ផ្នែក 5, ផ្នែករង L ដែលមានសិទ្ធិទទួលបានការផ្លាស់ប្តូរ ទីកន្លែងសង្គ្រោះបន្ទាន់ ប្រសិនបើៈ អ្នកជួលលំនៅដ្ឋានជឿជាក់ដោយសមហេតុផលថា មានការគំរាមកំហែងពីការធ្វើឱ្យមានគ្រោះថ្នាក់ ដែលជិតកើតមានឡើង ពីអំពើហិង្សាបន្ថែមទៀត ប្រសិនបើអ្នកជួលលំនៅដ្ឋាននៅតែស្ថិតនៅក្នុងលំនៅដ្ឋានដូចគ្នា។ ប្រសិនបើអ្នកជួលលំនៅដ្ឋានជាជនរងគ្រោះនៃការរំលោភផ្លូវភេទនោះ អ្នកជួលលំនៅដ្ឋានអាចមានសិទ្ធិស្របច្បាប់ចំពោះការផ្លាស់ប្តូរទីកន្លែង បើការរំលោភផ្លូវភេទបានកើតឡើងនៅលើបរិវេណលំនៅដ្ឋាននានានៅក្នុងរយៈពេល 90 ថ្ងៃនៃថ្ងៃប្រតិទិន មុនការស្នើសុំការផ្លាស់ប្តូរទីកន្លែងសង្គ្រោះ បន្ទាន់។
អ្នកជួលលំនៅដ្ឋានដែលស្នើសុំការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់ ត្រូវស្នើសុំការផ្លាស់ប្តូរទីកន្លែងច្បាស់លាស់ ដោយស្របតាមនីតិវិធីនានា ដែលមានចែងក្នុងផែនការនេះ។
អ្នកជួលលំនៅដ្ឋាននានាដែលមិនមានស្ថានភាពល្អ នៅតែអាចស្នើសុំការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់ ប្រសិនបើពួកគេបំពេញតាមតម្រូវការទាមទារភាពមានសិទ្ធិទទួលបាននៅក្នុងផ្នែកនេះ។

### ឯកសារស្នើសុំការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់

ដើម្បីស្នើសុំការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់ អ្នកជួលលំនៅដ្ឋានត្រូវជូនដំណឹងដល់ការិយាល័យគ្រប់គ្រងក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP និងដាក់សំណើជាលាយលក្ខណ៍អក្សរសម្រាប់ការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់ទៅ **[ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ដើម្បីបញ្ចូលទីកន្លែង]**។ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP នឹងផ្តល់ជូនកន្លែងស្នាក់នៅសមរម្យតាមគោលនយោបាយនេះ សម្រាប់បុគ្គលដែលមានពិការភាព។ សំណើជាលាយលក្ខណ៍អក្សររបស់អ្នកជួលលំនៅដ្ឋានផ្លាស់ប្តូរទីកន្លែងសម្រាប់ការសង្គ្រោះ បន្ទាន់ ត្រូវរាប់បញ្ចូលៈ

1. របាយការណ៍ដែលបង្ហាញថា អ្នកជួលលំនៅដ្ឋានជឿជាក់ដោយសមហេតុផល ថាមានការគំរាមកំហែងពីការធ្វើឱ្យមាន
   គ្រោះថ្នាក់ដែលជិតកើតមានឡើងពីអំពើហិង្សាបន្ថែមទៀត ប្រសិនបើអ្នកជួលលំនៅដ្ឋាននៅតែស្ថិតនៅក្នុងលំនៅដ្ឋានដែលជាកន្លែងស្នាក់នៅដដែល ដែលជួយដោយកម្មវិធីរបស់ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP; ឬ
2. របាយការណ៍ដែលអ្នកជួលលំនៅដ្ឋានជាជនរងគ្រោះនៃការរំលោភផ្លូវភេទ ហើយបញ្ហានោះការរំលោភផ្លូវភេទបានកើតឡើង នៅលើបរិវេណលំនៅដ្ឋាននានានៅក្នុងរយៈពេល 90 ថ្ងៃនៃថ្ងៃប្រតិទិន មុនការស្នើសុំពីអ្នកជួលលំនៅដ្ឋានផ្លាស់ប្តូរទីកន្លែង សង្គ្រោះបន្ទាន់។

### ការរក្សារឿងសម្ងាត់

ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP នឹងរក្សាព័ត៌មានសម្ងាត់ណាមួយ ដែលអ្នកជួលលំនៅដ្ឋានដាក់សំណើសុំការផ្លាស់ប្តូរទីកន្លែង សង្គ្រោះបន្ទាន់ និងព័ត៌មានអំពីការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់នោះ លុះត្រាតែអ្នកជួលលំនៅដ្ឋានផ្តល់ជូនលិខិតអនុញ្ញាតជា លាយលក្ខណ៍អក្សររបស់ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ដើម្បីបញ្ចេញឱ្យដឹងព័ត៌មានតាមពេលវេលាកំណត់ ឬការបញ្ចេញ ឱ្យដឹងព័ត៌មានដែលកំណត់ដោយច្បាប់ ឬតម្រូវឱ្យមានសម្រាប់ការប្រើប្រាស់នៅក្នុងដំណើរការនីតិវិធី

បណ្តេញចេញ ឬសវនាការដែលទាក់ទងនឹងការបញ្ចប់ជំនួយពីកម្មវិធីដែលបានធានា។ ហើយនេះរួមបញ្ចូលទាំងការរក្សាការសម្ងាត់អំពីទីតាំងថ្មីនៃលំនៅដ្ឋានស្នាក់នៅរបស់អ្នកជួលលំនៅដ្ឋាន ប្រសិនបើមានការផ្តល់ជូនពីបុគ្គល ដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួប បុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ប្រឆាំងអ្នកជួលលំនៅដ្ឋាន។ សូមមើលសេចក្តីជូនដំណឹងអំពីសិទ្ធិកាន់កាប់ ដែលស្ថិតក្រោមច្បាប់ស្តីពីអំពើហិង្សាលើស្ត្រី សម្រាប់អ្នកជួលលំនៅដ្ឋានទាំងអស់ សម្រាប់ព័ត៌មានបន្ថែមទៀតអំពីការទទួលខុសត្រូវរបស់ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ដើម្បីរក្សាព័ត៌មានសម្ងាត់ដែលទាក់ទងទៅនឹងឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។

### ការកំណត់ពេលវេលា និងភាពអាចប្រព្រឹត្តទៅបានចំពោះការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់

ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP  មិនអាចធានាថាការស្នើសុំការផ្លាស់ប្តូរទីកន្លែង នឹងត្រូវអនុម័ត ឬថាតើវាត្រូវចំណាយពេលយូរប៉ុណ្ណា ដើម្បីដំណើរការការស្នើសុំការផ្លាស់ប្តូរទីកន្លែងមួយ។  ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP នឹងមានដំណើរការប្រព្រឹត្តទៅយ៉ាងឆាប់រហ័សដែលអាចធ្វើបានដើម្បីផ្លាស់ប្តូរទីកន្លែងអ្នកជួលលំនៅដ្ឋាន ដែលជាជនរងគ្រោះនៃអំពើ ហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ទៅកាន់លំនៅដ្ឋានមួយផ្សេងទៀត ដែលអាស្រ័យលើលទ្ធភាព និងសុវត្ថិភាពលំនៅដ្ឋានផងដែរ។ ប្រសិនបើអ្នកជួលលំនៅដ្ឋានជឿជាក់ដោយសមហេតុផលថាការផ្លាស់ប្តូរទីកន្លែងសង្គ្រោះបន្ទាន់ដែលបានស្នើសុំនោះ មិនមានសុវត្ថិភាពទេនោះ អ្នកជួលលំនៅដ្ឋានអាចស្នើសុំការផ្លាស់ប្តូរទីកន្លែងទៅលំនៅដ្ឋានផ្សេងគ្នា។ ប្រសិនបើលំនៅដ្ឋានមួយដែលអាចមាននោះ អ្នកជួលលំនៅដ្ឋានដែលបានផ្លាស់ប្តូរទីកន្លែង ត្រូវយល់ព្រមគោរពតាមការកំណត់ពេលវេលា និងលក្ខខណ្ឌនានាដែលគ្រប់គ្រងការកាន់កាប់កម្មសិទ្ធិនៅក្នុងលំនៅដ្ឋាន ដែលក្នុងនោះអ្នកជួលលំនៅដ្ឋានត្រូវបានផ្លាស់ប្តូរទីកន្លែង។ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មិនអាចប្តូរទីកន្លែងសម្រាប់អ្នកជួលលំនៅដ្ឋានទៅលំនៅដ្ឋានដោយឡែកឡើយ ប្រសិនបើអ្នកជួលលំនៅដ្ឋានមិនមាន ឬមិនអាចបំពេញលក្ខខណ្ឌចំពោះលំនៅដ្ឋាននោះ។

ប្រសិនបើក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មិនមានលំនៅដ្ឋានសុវត្ថិភាព និងមិនអាចមានសម្រាប់អ្នកជួលលំនៅដ្ឋានដែល ត្រូវការសង្គ្រោះបន្ទាន់ ដែលមានសិទ្ធិស្របច្បាប់នោះ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP នឹងជួយអ្នកជួលលំនៅដ្ឋានក្នុងការស្វែង រកឃើញអ្នកផ្តល់សេវាកម្មលំនៅដ្ឋានផ្សេងទៀត ដែលអាចមានលំនៅដ្ឋានសុវត្ថិភាព និងដែលអាចមានសម្រាប់អ្នកជួលលំនៅដ្ឋានអាចផ្លាស់ប្តូរទីលំនៅ។  តាមសំណើរបស់អ្នកជួលលំនៅដ្ឋាន ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP នឹងជួយអ្នកជួលលំនៅដ្ឋានក្នុង ការទាក់ទងអង្គការមូលដ្ឋាន ដែលផ្តល់ជំនួយដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ដែលភ្ជាប់ទៅនឹងផែនការនេះ។

### សុវត្ថិភាព និងសន្តិសុខសម្រាប់អ្នកជួលលំនៅដ្ឋាន

ដំណើរការនៃការផ្លាស់ប្តូរទីកន្លែងដែលមិនទាន់សម្រេច និងការផ្លាស់ប្តូរទីកន្លែងជាក់ស្តែង ប្រសិនបើដំណើរការនេះត្រូវបានអនុម័ត និងកើតឡើងនោះ អ្នកជួលលំនៅដ្ឋានត្រូវបានជម្រុញឱ្យមានការចាត់វិធានការប្រុងប្រយ័ត្នជាមុន ដែលសមហេតុផលទាំងអស់ ដើម្បីមានសុវត្ថិភាព។

សម្រាប់ជំនួយក្នុងការបង្កើតផែនការសុវត្ថិភាព អ្នកជួលលំនៅដ្ឋានដែលជាជនរងគ្រោះ ឬជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ត្រូវបានលើកទឹកចិត្តឱ្យទាក់ទងតាមបណ្តាញទូរស័ព្ទទាន់ហេតុការណ៍អំពើហិង្សាក្នុងគ្រួសារថ្នាក់ជាតិ តាមលេខ 1-800-799-7233 ឬទីជម្រកពីនៃអំពើហិង្សាក្នុងគ្រួសារនៅមូលដ្ឋាន។ សម្រាប់ជនពិការគថ្លង់ បណ្តាញទូរស័ព្ទទាន់ហេតុការណ៍នោះ អាចប្រើបាន តាមការហៅទូរស័ព្ទលេខ 1-800-787-3224 (TTY) ។

អ្នកជួលលំនៅដ្ឋានដែលជាជនរងគ្រោះនៃការរំលោភផ្លូវភេទ ការចាប់រំលោភ ដែលអាចទាក់ទងតាមបណ្តាញទូរស័ព្ទទាន់ហេតុការណ៍

អំពីការរំលោភផ្លូវភេទថ្នាក់ជាតិរបស់បណ្តាញថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងការរំលោភបំពាន និងការសេពកាមរវាងបុរស និងស្ត្រី ជាប់សាច់ញាតិ តាមលេខទូរស័ព្ទ 800-656-HOPE, ឬក៏ចូលទៅបណ្តាញទាន់ហេតុការណ៍តាមអេឡិកត្រូនិក តាមវែបសាយ https://ohl.rainn.org/online/.

អ្នកជួលលំនៅដ្ឋានដែលជាជនរងគ្រោះ ឬជាជនរងគ្រោះពីការឈ្លបចាប់ ដែលស្វែងរកជំនួយនោះ អាចមកជួបនៅមជ្ឈមណ្ឌលជាតិ សម្រាប់ជនរងគ្រោះនៃមជ្ឈមណ្ឌលធនធានការឈ្លបចាប់ដែលជាអំពើឧក្រិដ្ឋកម្ម តាមវែបសាយ https://www.victimsofcrime.org/our-programs/stalking-resource-center.

**ឯកសារភ្ជាប់៖** អង្គការមូលដ្ឋានដែលផ្តល់ជំនួយដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរស និងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។